**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២២ **ឯកឧត្តមបណ្ឌិត ផនខាំ វីផាវ៉ាន់** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានផ្ញើលិខិតថ្លែងអំណរគុណ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារដូចខាងក្រោម ៖

«ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រ ជូនចំពោះ **សម្តេចតេជោ** ដែលបានទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ ក្នុងឱកាសដែលខ្ញុំបានទៅបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នៅចុងខែវិច្ឆិកា ឆ្នាំ២០២១កន្លងទៅ និងការផ្តល់ជំនួយចំពោះសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សម្រាប់ការពារទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសឡាវ រួមមានថវិកាចំនួន ១៣លានដុល្លារអាមេរិក វ៉ាក់សាំងចំនួន ៥០០.០០០ដូស និងរថយន្តដឹកវ៉ាក់សាំងចំនួន ១៣គ្រឿង។ ថ្ងៃនេះ នៅច្រកទ្វារព្រំដែនអន្តរជាតិណាងណុកខៀន-ត្រពាំងក្រៀលមានពិធីប្រគល់-ទទួលរថយន្តដឹកវ៉ាក់សាំងចំនួន ១០គ្រឿងបន្ថែមទៀត បន្ទាប់ពីមានពិធីប្រគល់-ទទួលនូវរថយន្តដឹកវ៉ាក់សាំង ចំនួន ០៣គ្រឿង កាលពីចុងខែធ្នូ ឆ្នាំ២០២១ កន្លងទៅ ។

ក្នុងនាមបក្ស រដ្ឋាភិបាល និងប្រជាជនឡាវ ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណយ៉ាងស្មោះត្រង់ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** គណបក្សប្រជាជនកម្ពុជា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលផ្តល់ជំនួយចំពោះសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជាពិសេសក្នុងពេលដែលប្រទេសយើងទាំងពីរកំពុងប្រឈមនឹងការឆ្លងរាលដាលយ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ហើយកម្ពុជាខ្លួនឯងនៅតែមានទឹកចិត្ត ដោយបានផ្តល់ជំនួយដូចបានជម្រាបជូនខាងលើ ដល់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលជាផ្នែកមួយនៃការចូលរួមជួយឱ្យយើងខ្ញុំអាចឈានទៅសម្រេចគោលដៅនៃការចាក់វ៉ាក់សាំងជូនពលរដ្ឋឡាវតាមការគ្រោងទុក ។

ជំនួយដ៏ថ្លៃថ្លាទាំងនេះ បានបង្ហាញឱ្យឃើញនូវសេចក្តីព្រួយបារម្ភ ការយកចិត្តទុកដាក់និងទឹកចិត្តជ្រះថ្លារបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលមានចំពោះរដ្ឋាភិបាល និងប្រជាជនឡាវក៏ដូចជាសបញ្ជាក់នូវទំនាក់ទំនងមិត្តភាពដ៏ស្និទ្ធស្នាល សាមគ្គីភាពជាប្រពៃណីដែលមានជាយូរលង់មកហើយ និងកិច្ចសហការក្នុងនាមប្រទេសភូមិផងរបងជាមួយ ក្នុងស្មារតីភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងស្ថិតស្ថេររឹងមាំរវាងប្រទេសយើងទាំងពីរឱ្យកាន់តែរីកចម្រើន និងប្រកបដោយផ្លែផ្កាជានិរន្តរ៍ ។

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ខ្ញុំសូមប្រសិទ្ធពរជ័យ ជូន **សម្តេចតេជោ** សូមប្រកបដោយសុខភាពល្អបរិបូរ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ចដ៏ឧត្តុងឧត្តម និងដ៏ខ្ពង់ខ្ពស់បំផុត»៕

ថ្ងៃសៅរ៍ ១០កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២